# បច្ចេកទេសបណ្តុះផ្សិតចំបើងពីកំប៉ុស្តចំបើង

ពពួកផ្សិតអាចដុះនៅលើសរីរាង្គរុក្ខជាតិដែលពុករលួយក្នុងលក្ខខ័ណ្ឌអាកាសធាតុ (សំណើម និង កំដៅ ) ដែលសមស្របទៅតាមប្រភេទនៃការលូតលាស់របស់វា ។

ផ្សិតចំបើងគេអាចធ្វើការបណ្តុះបាននៅលើចំបើងជញ្ជ្រាំងស្រូវ អាចម៍រណា ដើមចេក ស្លឹកចេកក្រៀម សំបកឈូក សំបកសណ្តែកបាយ សណ្តែកសៀង សំបកដំឡូងមី កាកអំពៅ កំប្លោកស្ពូត ស្រកីដូង និងពីកំទេចកំទីស្លឹករុក្ខជាតិ ស្មៅ ដោយលាយជាមួយនឹងសារធាតុជំនួយបន្ថែមមួយចំនួនទៀត ។

បច្ចេកទេសថ្មីៗ នាពេលបច្ចុប្បន្នគេអាចបណ្តុះផ្សិតចំបើងពីកំប៉ុស្តចំបើងដែលអាចធ្វើបានទាំងរដូវប្រាំង និង រដូវវស្សាពេញ១ឆ្នាំ ហើយពេលដុំកំប៉ុស្តចំបើងអស់ជាតិលែងដុះអាចយកទៅដាក់មេបណ្តុះធ្វើឡើងវិញបានផលល្អជាបន្តទៀត ។



ចំបើង



ផ្សិតចំបើងដុះលើដុំកំប៉ុស្តចំបើង



**១-វិធីបណ្តុះអាស្រ័យទៅតាមទីកន្លែងដែលត្រូវព្យួរដុំចំបើង**

មាន ៣ វិធី ដែលអាចធ្វើការជ្រើសរើស

**១-១.វិធីព្យួរក្រោមផ្ទះ រឺសង់រោងទាបៗក្បែរលំនៅដ្ឋាន**

អាចសង់រោងទាបៗនៅក្រោមផ្ទះដោយចំណាយធនធានតិចតួចធ្វើអំពីឈើ ឬ ឬស្សី មានសរសរជន្ទល់ បង្គង ស្នួ ទំពក់ព្យួរ មានកៅស៊ូប្លាស្ទិក រឺ ក្រណាត់សំរាប់គ្របបង្ហប់ពីលើ ។



វិធីព្យួរក្រោមផ្ទះ



Prepared by Mr. Pith Khon Hel TA and PFP staff ASDP of Kampong Cham

### ១-២. វិធីព្យួរក្រោមដើមឈើ

ត្រូវមានកងដែករាងរង្វង់ ថង់ច្រកស្រោបពីក្រៅដុំចំបើង រក្សាសំណើមកុំអោយប៉ះខ្យល់ ខ្សែសង្រែក និង ទំពក់សំរាប់ព្យួរនៅក្រោមដើមឈើ ។

### ១-៣. វិធីជីករណ្តៅ

ត្រូវជីករណ្តៅដូចត្រង់សេប្រើឈើ ឬ ឫស្សីធ្វើជាបង្គង ស្នួរសំរាប់ព្យួរដុំចំបើង ដោយលៃយ៉ាងណាធ្វើអោយងាយស្រួលដល់ការបេះប្រមូលផល ប្រើស្លឹកដូង ឬ មែកឈើគ្របពីលើ ។ វិធីនេះបើធ្វើលើកទីពីរត្រូវដុតសំលាប់មេរោគក្នុងរណ្តៅជាមុនសិន ។

## ២-សំភារៈដែលត្រូវការប្រើប្រាស់ក្នុងការបណ្តុះផ្សិតចំបើង

**សំភារៈដែលត្រូវការ**

- កៅស៊ូប្លាស្ទិកមាន២ស្រទាប់ (ខ្នាតទទឹង ២ម៉ែត្រ )ប្រវែង ១២ម៉ែត្រ
- កៅស៊ូប្លាស្ទិកមាន២ស្រទាប់ (ខ្នាតទទឹង ៨តឹក ) ១០ គក្រ
- ខ្សែនីឡុងសំរាប់ចងជាសង្រែកព្យួរថង់ល្បាយ ៤ គក្រ
- កងដាក់មាត់ថង់ (បំពង់ទីបជ័រទំហំ ៥៥ មម ) ២ ដើម
- ជញ្ជីង ១
- បំពង់ស្នប់បាញ់ទឹក ១
- ធុងស្រោចក្បាលផ្កាឈូក ១
- ធុងជ័រមានគំរបបិទជិត និងមានរ៉ូប៊ីណេបង្ហូរចំណុះ ២០ លីត្រ ១
- កៅស៊ូកង ស្កុត ០.៥ គក្រ និង ២ ដុំ
- សសៃរដែក (ទំហំ ៤ លី) សំរាប់ធ្វើរង្វង់កង និងទំពក់ព្យួរ ៣គក្រ
- តង់សំរាប់ក្រាលលាយល្បាយ និងរុំបង្ហប់ដុំកំប៉ុស្តចំបើង ១
- ឬស្សីសំរាប់ធ្វើស្នួ ៤ ដើម
- ពុម្ពធ្វើអំពីដែក ឬ ឈើសំរាប់ជាន់កំប៉ុស្តចំបើងជាដុំ ១
- ធុងសំរាប់ចំហុយ (ធុងសាំង ) ១
- ចង្ក្រានសំរាប់ចំហុយ ១













## ៣-វិធីបណ្តុះផ្សិតចំបើងដោយសង់រោងព្យួរក្រោមផ្ទះ

### ៣-១. ការសង់រោងទាបនៅក្រោមផ្ទះដើម្បីព្យួរដុំចំបើង

-សាងសង់រោងយោងតាមធនធានដែលមាន ពីឈើ ឬ ឫស្សី ដោយមានសរសរជន្ទល់ បង្គង ស្នួ

-រោងព្យួរផ្សិតធុនល្មមមានទទឹង ១.៥ម៉ែត្រ x បណ្តោយ ៨ម៉ែត្រ សរសរកណ្តាល កំពស់ ១,២៥ ម៉ែត្រ និងសរសរសងខាងកំពស់ 0,៩ ម៉ែត្រ មានឈើស្ទួ ៤ ជួរអាចព្យួរដុំចំបើងបាន ៨០ ដុំ (១ជួរ ២០ដុំ) ។

-ដំបូលត្រូវគ្របដោយកៅស៊ូប្លាស្ទិកទទឹង ៤ ម៉ែត្រ (ប្រើកៅស៊ូប្លាស្ទិកទទឹង ២ម៉ែត្រ ដែលមាន ២ស្រទាប់រះជា២) ប្រវែងបណ្តោយអោយវែងជាងបណ្តោយរោង ៤ ម៉ែត្រដើម្បីអាចទាញសង្កត់ជើងដល់ដី ។



ការរៀបចំស្ទួ



ការគ្របដោយប្លាស្ទិក

### ៣-២.វិធីទី ១  ការលាយល្បាយដោយប្រើជីអ៊ុយរ៉េ

| | |
|---|---|
| - ចំបើង | ១០០ គក្រ |
| - កន្ទក់ម៉ត់ | ៨ គក្រ |
| - ចុងអង្ករ | ១ គក្រ |
| - កំបោរស | 0.៥-0.៧ គក្រ |
| - ជីអ៊ុយរ៉េ(លាយជាមួយទឹកស្រោច) | 0.៥-0.៦ គក្រ |
| - ទឹកសំរាប់ស្រោច | ៥០-៦០% នៃល្បាយ |

### ៣-៣.វិធីទី ២ ការលាយល្បាយដោយប្រើកំប៉ុស្តទឹក

| | |
|---|---|
| - ចំបើង | ១០០ គក្រ |
| - កន្ទក់ម៉ត់ | ៨ គក្រ |
| - ចុងអង្ករ | ១ គក្រ |
| - កំបោរស | 0.៥-0.៧ គក្រ |

- កំប៉ុស្តទឹកសំរាប់ផ្សើមល្បាយ ៥០-៦០% នៃល្បាយ (ត្រូវរៀបចំផ្សំធ្វើមុនគេ) រយៈពេល ៨ថ្ងៃ ។

### ៣-៤.វិធីធ្វើកំប៉ុស្តទឹក

- <u>ល្បាយ ( ក )</u>

- ដឹមមោកស្ងួត ១ គក្រ

- អាចម៍គោក្រៀម ១ គក្រ
- កន្ទក់ម៉ត់ ១ គក្រ
- ស្ករស ឬ ស្ករត្នោត ៣ ស្លាបព្រាបាយ
- ទឹក ២ កែវ

លាយល្បាយអោយសើមល្មមពូតបាន ហើយខ្ទប់ដោយក្រណាត់ស្អាតទុកផ្អាប់រយះពេល ៤ថ្ងៃ បានជា**ល្បាយ(ក)** ។

- **<u>ល្បាយ ( ខ )</u>**

- កាកស្ករ ១ គក្រ
- ទឹក ១០ លីត្រ

ដាក់ចូលក្នុងធុងជ័រដែលមានគំរបបិទជិតហើយកូរអោយរលាយចូលគ្នាសព្វបានជា **ល្បាយ(ខ)** ។

- **<u>ល្បាយ ( គ )</u>**

- ដាក់ល្បាយ (**ក**) ទាំងកញ្ចប់ចូលក្នុងល្បាយ (**ខ**) កូរអោយសព្វទុកក្នុងធុងជ័រដែលមានគំរបបិទជិតរយះពេល ៤ថ្ងៃ អាចយកមកប្រើបានជា **ល្បាយ** (**គ**) គឺជា **កំប៉ុស្តទឹក** (សង្កេតមើលបើមានពពុះគឺល្បាយផ្សំបានល្អ) សំរាប់លាយជាមួយទឹកស្រោចផ្សើមលើល្បាយ ។ ដោយប្រើចំណុះ ១ ដបទឹកសុទ្ធ លាយជាមួយស្ករ ០.២៥គក្រ និងទឹកស្អាតចំនួន២០លីត្រ

**៤-វិធីលាយវត្ថុធាតុដើមជាល្បាយ**

- ក្រាលកៅស៊ូតង់សំរាប់លាយល្បាយ
- ហើយពង្រាយចំបើង ១០០ គ.ក្រ ជាស្រទាប់ៗ រួច រោយកន្ទក់ម៉ត់ ១០ គ.ក្រ រោយកំបោរស 0,៥0គ.ក្រ
- លាយច្របល់ធាតុផ្សំទាំងនោះអោយសព្វល្អ
- ស្រោចទឹកល្បាយដែលលាយពីកំប៉ុស្តទឹកលើធាតុផ្សំ ទាំងនោះអោយសព្វល្អ និងអោយមានសំណើម ពី ៦០ ទៅ ៧០ % ។



ការលាយល្បាយជាមួយទឹកជីកំប៉ុស្តិ

- រួចប្រមូលល្បាយជាគំនរហើយយកតង់ ឬសំពត់កៅស៊ូគ្របអោយជិតផ្អាប់ទុក៣យប់ទៅ ១ អាទិត្យ
- មុនយកល្បាយទៅជាន់ពុម្ពត្រូវច្របល់ល្បាយអោយសព្វម្តងទៀត



ការផ្អាប់



ការជាន់ពុម្ពជាដុំ